PRIMARK

# TELL US

**បើលោកអ្នកមានកង្វល់នៅកន្លែងធ្វើការ លោកអ្នកអាចទាក់ទង Primark ដោយប្រើខ្សែទូរសព្ទទាន់ហេតុការណ៍ TELL US ដោយឥតគិតថ្លៃ ឬវេបសាយ ឬកម្មវិធីតាមទូរសព្ទរបស់យើង។ Primark យើងត្រៀមចាំស្តាប់កង្វល់របស់លោកអ្នកដោយរក្សាភាពអនាមិក និងការសម្ងាត់។**

## តើនរណាអាចប្រើប្រាស់ TELL US បាន

គ្រប់គ្នាអាចទាក់ទង Primark ដោយប្រើខ្សែទូរសព្ទទាន់ហេតុការណ៍ Tell Us តាមវេបសាយ ឬតាមកម្មវិធីតាមទូរសព្ទបាន។ ឧទាហរណ៍ អ្នកធ្វើការពេញម៉ោង ក្រៅម៉ោង ឬកម្មករមានកិច្ចសន្យារយៈពេលកំណត់ កម្មករបណ្តែត ឬអ្នកធ្វើការតាមរយៈទីភ្នាក់ងារ អ្នកធ្វើការតាមផ្ទះ អ្នកផ្ទេរការងារបណ្តោះអាសន្ន អ្នកហាត់ការងារ អ្នកស្ម័គចិត្ត បុគ្គលិកកម្មករផលិតកម្ម ឬបុគ្គលិកផ្ទះបាយ។ល។

## តើលោកអ្នកអាចប្រាប់អ្វីខ្លះដល់យើង (TELL US)

សូមប្រាប់យើង (TELL US) បើលោកអ្នកជឿថា លោកអ្នក ឬមិត្តរួមការងាររបស់លោកអ្នក កំពុងរងអំពើ មិនសមរម្យ ឬអយុត្តិធម៌នៅកន្លែងធ្វើការ ឬលោកអ្នកបានឃើញអាកប្បកិរិយាទុច្ចរិត ខុសច្បាប់ ឬអាចគ្រោះថ្នាក់នៅកន្លែងធ្វើការ រួមទាំងការបំពានគោលនយោបាយ Primark ទាក់ទងនឹងសិទ្ធិមនុស្ស បញ្ហាសីលធម៌ និងបរិស្ថាន។

ឧទាហរណ៍ លោកអ្នកគ្មានអារម្មណ៍ថា កន្លែងធ្វើការរបស់អ្នកមានសុវត្ថិភាព លោកអ្នកបានរងការរំលោភបំពានរាងកាយ ឬពាក្យសម្តី ឬប្រាក់ឈ្នួលរបស់លោកអ្នក ពុំបានបើកត្រឹមត្រូវ ។ល។

**ក្នុងករណីបន្ទាន់ សូមហៅទៅសេវាសង្គ្រោះបន្ទាន់ក្នុងមូលដ្ឋាន៖** [117]

សូមជ្រាបថា Tell Us មិនប្តូរផ្លាស់នីតិវិធី និងគោលនយោបាយនៃកន្លែងធ្វើការរបស់លោកអ្នកទេ (ដូចជាយន្តការបណ្តឹងតវ៉ា ឬនិតិវិធីរបស់សហជីព ឬតំណាងកម្មករ ដែលមាន)ហើយយើងស្នើឱ្យលោកអ្នកលើកពីកង្វល់របស់លោកអ្នក ទៅថ្នាក់គ្រប់គ្រង ប្រធានក្រុម ឬតំណាងកម្មកររបស់លោកអ្នក បើអ្នកគិតថា អាចទៅធ្វើបាន។

## អត្តសញ្ញាណរបស់លោកអ្នក

បើលោកអ្នកចែករំលែកបញ្ហាជាមួយយើង តាមរយៈ TELL US នោះយើងនឹងរក្សាអត្តសញ្ញាណរបស់លោកអ្នកជាសម្ងាត់ និងទប់ស្កាត់ផលវិបាកអវិជ្ជមាននានា ដែលបណ្តាលមកពីការតវ៉ារបស់លោកអ្នក។

## របៀបប្រាប់ TELL US

លោកអ្នកអាចប្រាប់ TELL US ដោយប្រើខ្សែទូរសព្ទទាន់ហេតុការណ៍ ឬចូលទៅវេបសាយ ឬទាញយកកម្មវិធីនៅលើទូរសព្ទរបស់លោកអ្នកបាន។ នេះជាព័ត៌មានលម្អិត៖

| **តាមរយៈការហៅទៅខ្សែទូរសព្ទទាន់ហេតុការណ៍របស់យើង៖** | **តាមរយៈអាសយដ្ឋានវេបសាយខាងក្រោម៖** | **តាមរយៈការទាញយកកម្មវិធីដោយប្រើ QR** កូដ **ខាងក្រោម៖** |
|---|---|---|
| លេខទូរសព្ទឥតគិតថ្លៃក្នុងមូលដ្ឋានដែលមាននៅលើផ្ទាំងផ្សព្វផ្សាយ និងគោលនយោបាយ TELL US | https://primark.speakup.report/tellus | |
| **ពេលត្រូវបានណែនាំ សូមបញ្ចូលលេខកូតនេះ៖ 106502** | | |
| ថតសារជាសំឡេង ឬសរសេរសារយ៉ាងលម្អិតនៃក្តីកង្វល់ របស់អ្នក ជាភាសាជាតិ | | |
| បន្ទាប់មក លោកអ្នកនឹងទទួលលេខកូតរឿងក្តី លេខកូតនេះជួយសំរាប់ផ្តល់ ព័ត៌មានបន្ថែម ឬតាមដានស្ថានភាព | | |
| លោកអ្នកនឹងទទួលបាន សារបញ្ជាក់ការបានទទួលបានក្តីកង្វល់របស់អ្នកក្នុងរយៈពេល 72 ម៉ោង បន្ទាប់មក Primark នឹងពិនិត្យមើលបញ្ហារបស់អ្នក | | |

**លទ្ធផលនៃរឿងក្តីកង្វល់របស់អ្នកនឹងត្រូវបានចែករំលែកលើប្រព័ន្ធ Tell Us ដូច្នេះសូមកុំភ្លេចចូលពិនិត្យក្នុងប្រព័ន្ធ**Tell Us **ជាទៀងទាត់ ដើម្បីពិនិត្យមើលវឌ្ឍនភាព ឬ ស្ថានភាព។**

*យើងអើពើចំពោះលោកអ្នក*
*ហើយយើងអើពើចំពោះកង្វល់របស់លោកអ្នក*